Animal Welfare.
Worldwide.

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
វិមានសន្តិភាពនៃរាជរដ្ឋាភិបាល
អគារលេខ៣៨ មហាវិថីសហព័ន្ធរុស្ស៊ី(១១០)
ភ្នំពេញ ប្រទេសកម្ពុជា

ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០

**សំណើញត្តិ ១.០០០.០០០ហត្ថលេខា ដើម្បីបញ្ឈប់ការជួញដូរសាច់ឆ្កែនៅអាស៊ីអាគ្នេយ៍**

**សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

តាងនាមយើងខ្ញុំតំណាងអង្គការ ហ្វ័រផរអន្តរជាតិ (FOUR PAWS International) និងប្រជាពលរដ្ឋជាង ១.០០០.០០០លាននាក់ នៅជុំវិញពិភពលោក និងដោយឡែកប្រជាពលរដ្ឋជាង ២០០.០០០នាក់ ដែលនៅតំបន់អាស៊ីអាគ្នេយ៍ សូមគោរពស្នើសុំ**សម្តេច** ដើម្បីហាមឃាត់ការជួញដូរសាច់ឆ្កែក្នុងបុព្វហេតុគាំពារសុខុមាលភាពសត្វ ក៏ដូចជាការពារសុខភាព និងសុវត្ថិភាពប្រជាជនកម្ពុជាផងដែរ។ តំណភ្ជាប់ញត្តិរបស់យើងខ្ញុំ អាចបើកបាននៅទីនេះ៖ https://help.four-paws.org/km-KH/បញ្ចប់ជំនួញសាច់ឆ្កែ-និងឆ្មានៅអាស៊ីអាគ្នេយ៍

បញ្ហាសំខាន់នេះ ប្រហែលជាចាំបាច់ត្រូវតែធ្វើឡើងឱ្យបានទាន់ពេលវេលាដោយសារតែជំងឺកូវីដ-១៩ កំពុងរាតត្បាតជាសាកល ខណៈការជួញដូរសត្វឆ្កែកំពុងដើរតួនាទីជាប្រភពក្នុងការបង្កជាជំងឺថ្មីៗទៀត។

ចាប់តាំងពីឆ្នាំ២០១៨ មកអង្គការហ្វ័រផរ (FOUR PAWS) និង អង្គការសង្គ្រោះសត្វកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលកម្ពុជា បាននិងកំពុងធ្វើការស៊ើបអង្កេតលើការជួញដូរសាច់ឆ្កែនៅទូទាំងប្រទេស។ ភស្តុតាងជាក់ស្តែងដែលយើងបានប្រមូលចងក្រងជាឯកសារ បង្ហាញឱ្យឃើញពីភាពសាហាវព្រៃផ្សៃយ៉ាងក្រៃលែងចំពោះសត្វដែលពាក់ព័ន្ធនឹងការជួញដូរទាំងនេះ ដោយក្នុងនោះរួមមានវិធីផ្សេងៗក្នុងការសម្លាប់សត្វដោយគ្មានអនាម័យ និងហានិភ័យធ្ងន់ធ្ងរបង្កឡើងពីការជួញដូរនេះដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់សុខភាពសាធារណៈដោយសារតែជំងឺឆ្កែឆ្កួត។

**VIER PFOTEN International**
gemeinnützige Privatstiftung
Linke Wienzeile 236
1150 Vienna | Austria

phone: +43-1-545 50 20-0
fax: +43-1-545 50 20-99
e-mail: office@four-paws.org
www.four-paws.org

UniCredit Bank Austria AG
IBAN: AT13 1200 0515 8388 8444
BIC: BKAUATWW
HG Wien: FN 227934y

FOUR PAWS
Animal Welfare.
Worldwide.

តាមរយៈការបោះពុម្ពផ្សាយលទ្ធផលរបស់យើង បានឈានដល់ការអំពាវនាវថ្នាក់ជាតិ និងអន្តរជាតិ ឱ្យចាត់វិធានការដើម្បីការពារសត្វឆ្កែដែលមិនមែនចាត់ទុកជាម្ហូបអាហារនោះទេ ប៉ុន្តែផ្ទុយទៅវិញជាដៃដ៏គូស្មោះត្រង់ ព្រមទាំងជាអ្នកការពារសុខភាពសាធារណៈ និងសន្តិសុខសង្គមផងដែរ។

ជំនួញសាច់ឆ្កែនៅកម្ពុជា បានជាប់ពាក់ព័ន្ធដល់ការសម្លាប់ និងបរិភោគសត្វឆ្កែរហូតដល់ទៅជាង ៣លានក្បាលក្នុងមួយឆ្នាំៗ ដែលសត្វទាំងនោះភាគច្រើនជាសត្វចិញ្ចឹមត្រូវបានលួចចាប់យកទៅ។ តាមការស្រាវជ្រាវបានបង្ហាញថា ប្រជាជនកម្ពុជាតិចជាង ១២% ទទួលទានសាច់ឆ្កែជាប្រចាំ ហើយការទទួលទាននេះទៀតសោតជាប្រវត្តិសាស្ត្រមិនមែនជាវប្បធម៌ខ្មែរឡើយ[1]។ ទោះបីជាយ៉ាងនេះក្តី ក៏ការជួញដូរនៅតែបន្តជាប់ពាក់ព័ន្ធនឹងការប្រមូលសត្វពីប្រភពនានាយ៉ាងច្រើនដែលមិនដឹងច្បាស់លាស់ពីស្ថានភាពសុខភាពថាមានជំងឺឬអត់ ការដឹកជញ្ជូនឆ្លងប្រទេស និងការនាំចូលនូវសត្វឆ្កែដែលមានផ្ទុកជំងឺឆ្កែឆ្កួត ទៅក្នុងបណ្តាខេត្ត-ក្រុងនានាដូចជាកំពង់ចាម និងភ្នំពេញ។ នៅគោលដៅចុងក្រោយសត្វឆ្កែត្រូវបានសម្លាប់នៅកន្លែងសត្តឃាតដ្ឋានដែលគ្មានអនាម័យដោយមធ្យោបាយយ៉ាងព្រៃផ្សៃដូចជាការជ្រមុជទឹក ការវាយសំពង ឬព្យួរកជាដើម។ រាល់សកម្មភាពអនុវត្តទាំងនេះ មិនត្រឹមតែបង្កការឈឺចាប់ចំពោះសត្វនោះទេ ថែមទាំងគ្មានមធ្យោបាយណាដែលអាចធានាបានថាការលក់សាច់សត្វដែលបានចាប់មករក្សាទុក និងសម្លាប់នៅក្រោមលក្ខខណ្ឌបែបនេះ មានសុវត្ថិភាពសម្រាប់មនុស្សទទួលទាននោះដែរ។ អង្គការសុខភាពពិភពលោក (WHO) បានគូសបញ្ជាក់យ៉ាងច្បាស់រួចមកហើយថា ការជួញដូរសត្វឆ្កែសម្រាប់ជាអាហារទទួលទានរបស់មនុស្ស ជាកត្តារួមចំណែកមួយដល់ការរីករាលដាលនៃជំងឺឆ្កែឆ្កួត ហើយវិទ្យាស្ថានប៉ាស្ទ័រ ក៏ទទួលស្គាល់ថាតម្រូវការចាំបាច់សម្រាប់ផែនការទប់ស្កាត់ជំងឺឆ្កែឆ្កួតគឺពាក់ព័ន្ធនឹងការចាក់វ៉ាក់សាំងការពារឆ្កែជាលក្ខណៈទ្រង់ទ្រាយធំ[2]។

លើសពីនេះ ការជួញដូរសាច់ឆ្កែនៅកម្ពុជា គឺជាការរំលោភបំពានយ៉ាងច្បាស់លើច្បាប់នៃព្រះរាជាណាចក្រកម្ពុជាស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ (នស/រកម/០១៦៦/០០៣) ជាពិសេសជំពូកទី៨ (សត្តឃាតដ្ឋាន និងអនាម័យ) ជំពូកទី៩ (ចរាចរណ៍សត្វ និងផលិតផលសត្វ) ជំពូកទី១១ (សុខុមាលភាពសត្វ) និងជំពូកទី១៩ (អធិការកិច្ច)[3]។ ជាពិសេសការសម្លាប់សត្វឆ្កែ គឺរំលោភលើអនុក្រឹត្យលេខ១០៨ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន និងការធ្វើអាជីវកម្មពិឃាតសត្វ និងកន្លែងកែច្នៃផលិតផលសត្វដំបូង។

នៅខែកក្កដា ឆ្នាំ២០២០ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប បានចេញលិខិតហាមឃាត់ការជួញដូរសាច់ឆ្កែដែលនេះជាការឆ្លុះបញ្ចាំងពីទស្សនៈដែលបានផ្សព្វផ្សាយជាសាកលនាពេលបច្ចុប្បន្ននេះ ថាឆ្កែគឺជាដៃគូ

---

[1] FOUR PAWS, ២០២០, របាយការណ៍សង្ខេបស្តីពីការបរិភោគសាច់ឆ្កែនៅកម្ពុជា

[2] វិទ្យាស្ថានប៉ាស្ទ័រ, ២០១៧, ជំងឺឆ្កែឆ្កួតនៅកម្ពុជា

[3] ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ (លេខ៖ នស/រកម/០១៦៦/០០៣), ២០១៦

Animal Welfare.
Worldwide.

មិនមែនអាហារទេ[4] ។ យើងរីករាយសាទរយ៉ាងក្រៃលែងសម្រាប់ជំហានជោគជ័យដំបូងដ៏សំខាន់នេះក្នុងការបង្កើតខេត្តមួយដែលគ្មានសាច់ឆ្កែដំបូងគេបង្អស់នៅកម្ពុជា ហើយការហាមឃាត់ទូទាំងប្រទេសនេះ គឺជាជំហានបន្ទាប់ដែលសមស្របដើម្បីជានាថាខេត្តផ្សេងៗទៀតនឹងអនុវត្តតាម។ ចាប់តាំងពីដើមឆ្នាំ២០១៩ អង្គការហ្វ័រផរ (FOUR PAWS) និងអង្គការសង្គ្រោះសត្វកម្ពុជា បាន និងកំពុងសហការជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (GDAHP) ដើម្បីផ្តល់ការគាំទ្រចំពោះការហាមឃាត់នេះ។

ចាប់តាំងពីមានការរាតត្បាតជំងឺកូវីដ-១៩ ចេញមកពីទីក្រុងវូហាន ប្រទេសចិនកាលពីចុងខែវិច្ឆិកាឆ្នាំ២០១៩[5] រដ្ឋាភិបាលនានានៅក្នុងតំបន់ បានចាត់វិធានការហាមឃាត់ការជួញដូរសាច់ឆ្កែ ដោយទទួលស្គាល់ថាវាមិនមែនជារឿងសមស្របសម្រាប់ការអនុវត្តក្នុងសម័យទំនើប និងការការពារសុខភាពមនុស្សពីជំងឺរាតត្បាតនាពេលអនាគតឡើយ។ ឧទាហរណ៍ទីក្រុងនានារបស់ប្រទេសចិនដូចជានៅទីក្រុងសិនជិន និងស៊ូហៃ បានដាក់បម្រាមទូទាំងទីក្រុងមិនឱ្យមានការទទួលទានសាច់ឆ្កែ និងឆ្មា ហើយ**ក្រសួងកសិកម្ម និងកិច្ចការជនបទរបស់ចិន បានដកសត្វឆ្កែចេញពីបញ្ជីប្រភេទសាច់បសុសត្វជាអាហារ ដោយបញ្ជាក់ថាសត្វឆ្កែគឺជា "សត្វដៃគូ"** មិនមែនជា "អាហារ" ទេ[6]។[7]

តាងនាមអង្គការនានាដែលបានចុះហត្ថលេខានៅទូទាំងពិភពលោក និងប្រជាជនចំនួន ១.០០០.០០០នាក់ដែលបានបញ្ចេញសំឡេងគាំទ្រនាពេលនេះ យើងខ្ញុំសូមគោរពស្នើសុំដោយទទូច សូមឱ្យរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការបង្ការជាបន្ទាន់ដោយ៖

- ហាមឃាត់ការជួញដូរ ការសម្លាប់ និងការបរិភោគសាច់ឆ្កែជាអចិន្ត្រៃយ៍នៅកម្ពុជា។
- ពង្រឹងច្បាប់ដែលមានស្រាប់ក្នុងការបិទកន្លែងសត្តឃាតដ្ឋានសត្វឆ្កែខុសច្បាប់ ដោយយោងទៅតាមច្បាប់ជាពិសេសអនុក្រឹត្យលេខ១០៨ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន និងការធ្វើអាជីវកម្មពិឃាតសត្វ និងកន្លែងកែច្នៃផលិតផលសត្វដំបូង ក្រោមសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។
- ចេញសេចក្តីថ្លែងការណ៍ជាសាធារណៈទាក់ទងនឹងគ្រោះថ្នាក់សុខភាពសាធារណៈដោយសារការសម្លាប់ និងការទទួលទានសាច់ឆ្កែ។

[4] សារព័ត៌មាន BBC, ២០២០, សាច់ឆ្កែ៖ ខេត្តដំបូងគេបង្អស់នៅកម្ពុជា ហាមឃាត់ការលក់ និងការទទួលទាន
[5] Business Insider, ២០២០, ប្រទេសចិនបានហាមឃាត់ការជួញដូរ និងការទទួលទានសាច់សត្វព្រៃ។ អ្នកជំនាញគិតថាជំងឺកូរ៉ូណាវីរុសកើតចេញពីសត្វរស់ចម្លងទៅមនុស្សនៅផ្សារមួយកន្លែង
[6] សារព័ត៌មាន BBC, ២០២០, ទីក្រុងសិនជិន ក្លាយជាទីក្រុងដំបូងបង្អស់នៅប្រទេសចិនដែលហាមឃាត់ការទទួលទានសាច់ឆ្កែ និងឆ្មា
[7] សារព័ត៌មាន International Business Times, ២០២០, ទីក្រុងស៊ូហៃប្រទេសចិន ក្លាយជាទីក្រុងទីពីរដែលហាមឃាត់ការទទួលទានសាច់ឆ្កែ និងឆ្មាជាអចិន្ត្រៃយ៍

FOUR PAWS

Animal Welfare.
Worldwide.

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំចំពោះការឆ្លើយតបដ៏ខ្ពង់ខ្ពស់របស់**សម្តេច**ទាក់ទងនឹងបញ្ហាបន្ទាន់ដ៏សំខាន់នេះ ហើយយើងខ្ញុំរំពឹងថា**សម្តេច**នឹងផ្តល់នូវការអនុញ្ញាតដ៏ខ្ពង់ខ្ពង់សម្រាប់កិច្ចជំនួបពិភាក្សាផ្ទាល់អំពីកិច្ចការផ្សេងៗដែលយើងខ្ញុំអាចជួយគាំទ្រដល់**សម្តេច** នាពេលខាងមុខ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត

ចូសែហ្វ ហ្វាប៊ីហ្គាន
នាយកប្រតិបត្តិ និងប្រធានក្រុមប្រឹក្សាភិបាល អង្គការហ្វ័រផរអន្តរជាតិ

**សូមគោរពផ្ញើជូនក្នុងនាមតំណាងអង្គភាពនានាដូចខាងក្រោម៖**
១- អង្គការសង្គ្រោះសត្វកម្ពុជា
២- សមាគមសុខុមាលភាពសត្វរាជធានីភ្នំពេញ
៣- សមាគមការពារសត្វកម្ពុជា

**ចម្លងជូន៖**
**ឯកឧត្តម វេង សាខុន**
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
លេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន ភ្នំពេញ ប្រទេសកម្ពុជា

**ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង**
រដ្ឋមន្ត្រីក្រសួងសុខាភិបាល
ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩)
សង្កាត់បឹងកក់២ ខណ្ឌទួលគោក ភ្នំពេញ ប្រទេសកម្ពុជា

**VIER PFOTEN International**
gemeinnützige Privatstiftung
Linke Wienzeile 236
1150 Vienna | Austria

phone: +43-1-545 50 20-0
fax: +43-1-545 50 20-99
e-mail: office@four-paws.org
www.four-paws.org

UniCredit Bank Austria AG
IBAN: AT13 1200 0515 8388 8444
BIC: BKAUATWW
HG Wien: FN 227934y

Animal Welfare.
Worldwide.


1. FOUR PAWS, ២០២០, របាយការណ៍សង្ខេបស្តីពីការបរិភោគសាច់ឆ្កែនៅកម្ពុជា, https://dogcatmeat.four-paws.org/the-truth/a-summary-report-on-dog-meat-consumption-in-cambodia
2. វិទ្យាស្ថានប៉ាស្ទ័រ, ២០១៧, ជំងឺឆ្កែឆ្កួតនៅកម្ពុជា, https://bit.ly/368lQuY
3. ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ (លេខ៖ នស/រកម/០១៦៦/០០៣), ២០១៦
4. សារព័ត៌មាន BBC, ២០២០, សាច់ឆ្កែ៖ ខេត្តដំបូងគេបង្អស់នៅកម្ពុជា ហាមឃាត់ការលក់ និងការទទួលទាន, https://www.bbc.com/news/world-asia-53334854
5. Business Insider, ២០២០, ប្រទេសចិនបានហាមឃាត់ការជួញដូរ និងការទទួលទានសាច់សត្វព្រៃ។ អ្នកជំនាញគិតថាជំងឺកូរ៉ូណាវីរុសកើតចេញពីសត្វរស់ចម្លងទៅមនុស្សនៅផ្សារមួយកន្លែង, https://www.businessinsider.com/china-bans-wildlife-trade-consumption-coronavirus-2020-2
6. សារព័ត៌មាន BBC, ២០២០, ទីក្រុងស៊ិនជិន ក្លាយជាទីក្រុងដំបូងបង្អស់នៅប្រទេសចិនដែលហាមឃាត់ការទទួលទានសាច់ឆ្កែ និងឆ្មា, https://www.bbc.com/news/world-asia-china-52131940
7. សារព័ត៌មាន International Business Times, ២០២០, ទីក្រុងស៊ូហៃប្រទេសចិន ក្លាយជាទីក្រុងទីពីរដែលហាមឃាត់ការទទួលទានសាច់ឆ្កែ និងឆ្មាជាអចិន្ត្រៃយ៍ https://www.ibtimes.com/chinas-zhuhai-permanently-bans-consumption-cat-dog-meat-second-city-do-so-2960225